# បេះដូងជនពិការ (ពាក្យប្រាំពីរ)

-រូបខ្ញុំពិតមែនតែពិការ តែចិត្តជ្រះថ្លាក្លាជួយអរ
ពេលឃើញម្ទឹះខ្មែរក្រៃលបវរ ពាក់អាវវាលកល្អប្រពៃ ។
-យុវក្មេងៗលេងម៉ូតូ ហ្វីណូ មីអូ យុវវ៉ៃយ
មើលទៅពួកគេពិតមានន័យ សប្បាយគ្មានភ័យរឿងទុក្ខា ។
-ពេលព្រឹកគេក្រោកពីព្រលឹម ពព្រាយញញឹមចូលសាលា
ដៃជើងស្រឡូនខ្ចីភក្ត្រា ហត្ថាកាន់ក្ដាប់ទូរស័ព្ទដៃ ។
-ខោអាវខើចខ្ចីថ្មីរលើប សន្ធាងទំនើបគ្រប់ម៉ូដថ្មៃ
ផើតលើជង្គង់រោមរ៉ៃៗ យប់ថ្ងៃខ្ញុំភ្លឹកនឹកកិត្តិយស ។
-ពេលខ្លះត្រសងហ្វូងសង្សារ ចូលហាងអាហារសម្រន់ពោះ
ខ្ញុំជនពិការកប់កេរ្តិ៍ឈ្មោះ បានជួយជាតិរស់ហួសប្រសើរ ។
-គូប្ដីភរិយាហៀវសប្បាយ ក្អាកក្អាយហ៊ឺហារកាយគ្រាន់បើ
ជាន់ឡានទំនើបលែងស្គាល់ដើរ ឬកពារប្រហើរស្មើឋានៈ ។
-ឃើញខ្មែរដូច្នេះខ្ញុំសប្បាយ សម្បូរប្រាក់ចាយផុតអប្បលក្ខណ៍
ខ្ញុំពិតរំភើបស្រើបអួលអាក់ ត្រេកអរដោយស្មគ្រ័ខ្នាក់ញញឹម ។
-ថ្វីត្បិតតែខ្ញុំរស់ខ្វះផ្ទះ ដៃខ្ញុំសំពះខ្មាសសង្ឃឹម
ខ្ញុំដេកតាមធ្លាហាលរលឹម ភ្លៀងភ្គរគ្រហឹមគំរាមចិត្ត ។
-តែខ្ញុំមិនដែលនឹកច្រណែន ឈ្នានីសជាផែនទាំក្រៀមស្វិត
ខ្ញុំរីតសាទរអស់ពីចិត្ត ក្នុងមួយជីវិតខ្ញុំមោទនៈ ។

ពៅ សុខ

០១២ ៩៨៨ ១៧៦